ទំនុកដំកើង ៣២:២-៣៣:២១

**មានពរហើយ មនុស្សណាដែលព្រះយេហូវ៉ាមិនរាប់ថាជាអ្នកមានទោស ជាអ្នកដែលគ្មានកលឧបាយនៅក្នុងចិត្តសោះ (ទំនុកដំកើង៣២:២)។**

ព្រះជាម្ចាស់ទ្រង់មិនទម្លាក់ទោសនៃអំពើបាប មកលើជនណាដែលជឿទុកចិត្តដល់ព្រះអម្ចាស់យេស៊ូវគ្រីស្ទទេ។ អំពើបាបទាំងអម្បាលមាណរបស់ជនដែលជឿលើព្រះអម្ចាស់យេស៊ូវ បានត្រូវផ្ទេរទៅលើរូបអង្គទ្រង់ហើយ។ គម្ពីររ៉ូម៤:២៥ ចែងថា "ដែលទ្រង់ត្រូវគេបញ្ជូនទៅឱ្យមានទោស ដោយព្រោះអំពើរំលងរបស់យើងរាល់គ្នា ហើយបានប្រោសឱ្យមានព្រះជន្មរស់ឡើងវិញ ប្រយោជន៍ឱ្យយើងរាល់គ្នាបានរាប់ជាសុចរិត"។ គម្ពីរ២កូរិនថូស៥:១៧ ចែងដែរថា "បានជាបើអ្នកណានៅក្នុងព្រះគ្រីស្ទ នោះឈ្មោះថាបានកើតជាថ្មីហើយ អស់ទាំងសេចក្ដីចាស់បានកន្លងបាត់ទៅ មើលគ្រប់ទាំងអស់បានត្រឡប់ជាថ្មីវិញ"។ ព្រះជាម្ចាស់ ជាព្រះនៃស្ថានសួគ៌ ជាព្រះដ៏ធំលើអស់ទាំងព្រះ ទ្រង់ផ្ដល់អភ័យឯកសិទ្ធិយ៉ាងខ្ពស់ដល់ជនដែលព្រមជឿដល់ព្រះអម្ចាស់យេស៊ូវគ្រីស្ទ។ ព្រះអម្ចាស់យេស៊ូវសុគតនៅលើឈើឆ្កាងជំនួសបាបរបស់អ្នកជឿដល់ព្រះអង្គ ទ្រង់រស់ឡើងវិញ ដើម្បីរក្សាអ្នកជឿព្រះអង្គអោយនៅតែមានសេចក្ដីស្មោះត្រង់នឹងទ្រង់។

ព្រះបាទដាវីឌ បង្ហើបអោយយើងដឹងពីអាថ៌កំបាំងដែលកើតឡើងដល់រូបលោក នៅពេលដែលលោកមានបំណងលាក់អំពើបាបទុកនៅក្នុងចិត្ត។ ក្នុងបទពិសោធន៍នោះ ព្រះបាទដាវីឌមានបន្ទូលថា:

> **កាលទូលបង្គំបានស្ងៀមនៅ នោះឆ្អឹងទូលបង្គំបានខ្សោះទៅ ដោយសារដំងូរដែលទូលបង្គំថ្ងូរជាដរាបរាល់ថ្ងៃ (ទំនុកដំកើង ៣២:៣)។**

ព្រះបាទដាវីឌ ជាក្សត្រដែលមានមហិទ្ធិឫទ្ធិ ព្រមទាំងមានកេរ្តិ៍ឈ្មោះជាងគេបង្អស់ ក្នុងចំណោមស្ដេចទាំងប៉ុន្មានដែលសោយរាជ្យនគរអ៊ីស្រាអែល និងស្រុកយូដាដែរ។ នាហ្មឺនមន្ត្រីគ្រប់ជាន់ថ្នាក់ និងប្រជានុរាស្ត្រ រាប់ទ្រង់ថា ជាស្ដេចប្រកបដោយទសពិធរាជធម៌។ ស្ដេចអង្គនេះ គង់លើបល្ល័ង្កសម្លឹងមើលមកពួកព្រាហ្មណ៍បុរោហិត និងពួកនាហ្មឺនមន្ត្រីគ្រប់ជាន់ថ្នាក់គិតនៅក្នុងចិត្តថា គ្មានអ្នកណាដឹងពីអំពើបាបលាក់កំបាំងដែលមាននៅក្នុងចិត្តរបស់លោកទេ។ ប៉ុន្តែ ទោះគ្មានអ្នកណាដឹងសោះក៏ដោយ បញ្ញាចិត្តរបស់លោក ចេះតែធ្វើអោយលោកនៅមិនសុខ។ លោកពណ៌នាថា ក្នុងប្រហោងឆ្អឹងរបស់លោក មានការឈឺចាប់ពើតយ៉ាងចុកចាប់។ ឯរូបរាងកាយរបស់លោកក៏ត្រូវស្គាំងស្គម បានជាពួកព្រាហ្មណ៍បុរោហិត និងពួកនាហ្មឺនសព្វមុខមន្ត្រីយល់ថា ព្រះបាទដាវីឌមានជម្ងឺអ្វីមួយ។ អ្នកផងទាំងពួងមិនបានដឹងថា នៅក្នុងចិត្តរបស់ព្រះ

បាទដាវីឌមានអំពើបាបលាក់កំបាំងទេ។ ស្តេចអង្គនេះ ព្យាយាមលាក់អំពើបាបនោះអស់ជាច្រើនខែថ្ងៃ។

**ដ្បិតព្រះហស្តនៃទ្រង់បានសង្កត់លើទូលបង្គំជាធ្ងន់ទាំងយប់ទាំងថ្ងៃ ជាតុទឹករបស់ទូលបង្គំបានត្រឡប់ទៅជារីងហួត ដូចនៅរដូវក្តៅ (ទំនុកដំកើង ៣២:៤)។**

បើលោកអ្នកពិតជាកូនរបស់ព្រះជាម្ចាស់មែន ហើយបើលោកអ្នកចង់ប្រព្រឹត្តអំពើបាបណាមួយ សូមធ្វើចុះ តែសូមជ្រាបអោយច្បាស់ថា លោកអ្នកមិនអាចរួចខ្លួនជាដាច់ខាត។ អ្នកជឿព្រះ ហើយនិងអ្នកមិនជឿព្រះខុសគ្នា ពេលគេប្រព្រឹត្តអំពើបាប។ បើលោក អ្នកមិនមែនជាអ្នកជឿដល់ព្រះអម្ចាស់យេស៊ូវ លោកអ្នកអាចប្រព្រឹត្តអំពើបាប ហើយអាចរួចខ្លួនមួយរយៈទំរាំគេចាប់បាន។ ប៉ុន្តែ ចំពោះលោកអ្នកដែលជាកូនរបស់ព្រះជាម្ចាស់វិញ មិនអាចគេចខ្លួនបានមួយរយៈណាទេ។ ព្រះហស្តរបស់ព្រះជាម្ចាស់សង្កត់ធ្ងន់មកលើចិត្តរបស់ព្រះបាទដាវីឌទាំងថ្ងៃទាំងយប់។ ដូច្នេះហើយ បានជាសាវ័កប៉ុលមានប្រសាសន៍ថា "បើសិនជាយើងរាល់គ្នាពិចារណាមើលក្នុងខ្លួនយើង នោះយើងមិនត្រូវជាប់ជំនុំជំរះទេ តែកាលណាយើងរាល់គ្នាត្រូវជាប់ជំនុំជំរះ នោះព្រះអម្ចាស់ទ្រង់វាយផ្ចាលយើងវិញ ដើម្បីកុំឱ្យយើងជាប់ទោសជាមួយនឹងលោកីយ៍ឡើយ" (១កូរិនថូស ១១:៣១-៣២)។ ការពិចារណាខ្លួនឯងមានន័យថា បើលោកអ្នកដឹងថាមានបាបនៅ

ក្នុងចិត្តហើយ ត្រូវជំរះខ្លួនឯងដោយលន់តួចំពោះព្រះអង្គ។ បើលោកអ្នកមិនជំរះខ្លួនឯងទេ ព្រះជាម្ចាស់នឹងជំរះយើងដោយការវាយផ្ចាល។ ព្រះជាម្ចាស់មិនបណ្តោយអោយយើងធ្វើអ្វីស្រេចនឹងចិត្តយើងចង់ទេ។

ព្រះបាទដាវីឌឆ្លងកាត់បទពិសោធន៍នេះផ្ទាល់ខ្លួន។ បន្ទាប់ពីទ្រង់បានប្រព្រឹត្តអំពើបាប ហោរាណាថាន់បានចូលមកបន្ទោសដល់ស្តេចអង្គនេះថា "...នៅទីក្រុង១មានមនុស្ស២នាក់ ម្នាក់ជាអ្នកមាន ម្នាក់ក្រីក្រ អ្នកដែលមាននោះ មានចៀមហើយនឹងគោយ៉ាងសន្ធឹក តែអ្នកដែលក្រគ្មានអ្វីសោះ មានតែកូនចៀម១ ដែលបានទិញមកចិញ្ចឹមប៉ុណ្ណោះ កូនចៀមនោះក៏ចំរើនធំឡើងនៅជាមួយនឹងគាត់ ហើយនឹងកូនគាត់ វាតែងស៊ីអាហារ ហើយផឹកពីពែងរបស់គាត់ ក៏ដេកនៅនាដើមទ្រូងគាត់ដែរ គាត់ទុកវាដូចជាកូនស្រីរបស់ខ្លួន គ្រានោះ មានអ្នកដំណើរម្នាក់មកឯមនុស្សអ្នកមាននោះ តែអ្នកមានមិនព្រមយកសត្វណាមួយពីហ្វូងចៀមហ្វូងគោរបស់ខ្លួន ដើម្បីនឹងចាត់ចែងរៀបចំទទួលអ្នកដំណើរ ដែលមកឯខ្លួននោះទេ គឺបានចាប់យកកូនចៀមរបស់អ្នកក្រីក្រនោះ ទៅចាត់ចែងទទួលអ្នកដែលមកនោះវិញ ដូច្នេះដាវីឌទ្រង់មានសេចក្តីខ្ញាល់ក្តៅឡើងចំពោះអ្នកនោះជាខ្លាំង ក៏មានបន្ទូលទៅណាថាន់ថា យើងស្បថដោយនូវព្រះយេហូវ៉ាដ៏មានព្រះជន្មរស់នៅថា មនុស្សណាដែលប្រព្រឹត្តដូច្នោះគួរស្លាប់ហើយ ត្រូវឱ្យវាសង១ជា៤ជំនួសចៀមនោះ ដោយព្រោះបានប្រព្រឹត្តឥតប្រណីដូច្នោះ នោះណាថាន់ទូលសបថា ឯមនុស្សនោះ គឺជាអង្គទ្រង់នេះហើយ ព្រះយេហូវ៉ា ជាព្រះនៃសាសន៍អ៊ីស្រាអែលទ្រង់មានបន្ទូលដូច្នេះថា អញបានចាក់ប្រេងតាំងឯងឡើងជាស្តេចនៃសាសន៍អ៊ីស្រាអែល

ក៏បានជួយឯងឱ្យរួចពីកណ្តាប់ដៃរបស់សូល" (២សាំយូអែល១២:១-៧)។ បន្ទាប់ពីបានឮពាក្យបន្ទោសនោះ ព្រះបាទដាវីឌលន់តួអំពើបាបរបស់ទ្រង់។

**ទូលបង្គំបានរ៉ាប់ទទួលអំពើបាបរបស់ទូលបង្គំនៅចំពោះទ្រង់ ឥតលាក់ការទុច្ចរិតរបស់ទូលបង្គំទុកឡើយ ទូលបង្គំបាននិយាយថា ទូលបង្គំនឹងលន់តួ អស់ទាំងការរំលងរបស់ទូលបង្គំដល់ព្រះយេហូវ៉ា ឯទ្រង់ក៏បានអត់ទោសចំពោះអំពើបាបនៃទូលបង្គំទៅ។ បង្អង់ (ទំនុកដំកើង៣២:៥)។**

ព្រះបន្ទូលនេះ ជាសេចក្តីបង្រៀនដល់លោកអ្នកក៏ដូចជារូបខ្ញុំដែរ។ បើលោកអ្នកដាច់ការប្រកបជិតស្និទ្ធជាមួយនឹងព្រះអង្គ ព្រះបាទដាវីឌលើកទឹកចិត្តដល់លោកអ្នកអោយបកមករកព្រះអង្គវិញ។ លោកយ៉ូហានបញ្ជាក់ថា "បើយើងលន់តួបាបវិញ នោះទ្រង់មានព្រះហឫទ័យស្មោះត្រង់ ហើយសុចរិត ប្រយោជន៍នឹងអត់ទោសបាបឱ្យយើង ហើយនឹងសំអាតយើង ពីគ្រប់អំពើទុច្ចរិតទាំងអស់ផង" (១យ៉ូហាន១:៩)។

**ដូច្នេះ ត្រូវឱ្យអស់អ្នកដែលកោតខ្លាចដល់ព្រះ បានអធិស្ឋានដល់ទ្រង់ នៅវេលាដែលនឹងរកទ្រង់ឃើញយ៉ាងនោះ កាលណា**

**ជំនន់ធំជន់ឡើង នោះប្រាកដជានឹងមិនដែលលិចមកដល់អ្នកនោះឡើយ (ទំនុកដំកើង៣២:៦)។**

ជំនន់ធំដែលព្រះបាទដាវីឌនិយាយក្នុងខខាងលើ ជាជំនន់ដែលព្រះជាម្ចាស់បញ្ជូនមកពន្លិចពិភពលោកនៅសម័យលោកណូអេ។ លោកណូអេឡើងលើទូក ពេលទឹកជំនន់ធំបានជន់លិចផែនដី។ ក្នុងខណៈនោះ មនុស្សរាប់ម៉ឺន រាប់សែននាក់ បានលង់ទឹកស្លាប់។ លោកណូអេ និងគ្រួសារមិនស្លាប់ទេ ពីព្រោះលោកស្នាក់នៅក្នុងទូកដែលព្រះជាម្ចាស់បង្គាប់អោយលោកធ្វើ។ សេចក្ដីជំនុំជំរះរបស់ព្រះជាម្ចាស់ មិនបានប៉ះពាល់ដល់លោកណូអេឡើយ។ ព្រះជាម្ចាស់ធ្វើការជំនុំជំរះនៅផែនដីនេះ។ ឯការជំនុំជំរះកន្លងមកមាន មួយ ការជំនុំជំរះដោយទឹកជំនន់ធំ។ មួយទៀត ការជំនុំជំរះដែលត្រូវកើតឡើងនៅពេលខាងមុខ ជាការជំនុំជំរះដោយភ្លើងឆេះកាល។ នៅពេលភ្លើងឆេះកាលធ្លាក់មកដល់ តើលោកអ្នកធ្វើដូចម្ដេចដើម្បីអោយបានរួចជីវិត? ខគម្ពីរខាងក្រោមនេះ ជម្រាបពីផ្លូវដែលលោកអ្នកត្រូវប្រកាន់យក។

**ទ្រង់ជាទីពំនួននៃទូលបង្គំ ទ្រង់នឹងការពារទូលបង្គំ ឱ្យរួចពីសេចក្ដីទុក្ខលំបាក ទ្រង់នឹងព័ទ្ធទូលបង្គំជុំវិញ ដោយទំនុកនៃសេចក្ដីសង្គ្រោះ។ បង្អង់ (ទំនុកដំកើង៣២:៧)។**

យើងត្រូវទទួលព្រះអម្ចាស់យេស៊ូវជាអង្គសង្គ្រោះរបស់យើង។ ចុងខ៧ យើងឃើញមានពាក្យសរសេរថា បង្អង់។ បង្អង់ មានន័យថាយើងត្រូវឈប់ ឈរ ហើយឈាន។ ឈប់មានន័យថា ប្រមូលអារម្មណ៍អោយស្ថិតនៅក្រោមឥទ្ធិពលនៃព្រះបន្ទូល។ ឈរ ដើម្បីក្រឡេកមើលនាយអាយ ដោយយកព្រះបន្ទូលសន្យារបស់ទ្រង់ទៅវាស់មើល។ បន្ទាប់មកយើងត្រូវឈានជំហានចេញទៅ ដោយប្រុងស្តាប់ក្រែងលោឮព្រះសូរសៀងរបស់ទ្រង់មកតម្រង់ជីវិតយើងបន្ថែមទៀត។ បង្អង់មានន័យថា យើងត្រូវពិចារណានូវបទចម្រៀងដែលយើងទើបនឹងបានច្រៀងរួចហើយ។ លោកអ្នកបងប្អូនអើយ សូមលោកអ្នកបងប្អូនមេត្តាពិចារណាម្តងទៀតថា តើលោកអ្នកមានការដាច់ទំនាក់ទំនងជាមួយព្រះជាម្ចាស់ដែរឬទេ? មួយទៀត ត្រូវសួរខ្លួនឯងថា តើលោកអ្នកត្រូវការទីពំនួនដែរឬ? បើត្រូវការព្រះជាម្ចាស់ទ្រង់ជាព្រះដែលអាចការពារលោកអ្នកបាន។

**អញនឹងបង្ហាត់បង្រៀនឱ្យឯងស្គាល់ផ្លូវដែលឯងត្រូវដើរ អញនឹងទូន្មានឯង ដោយភ្នែកអញមើលឯងជាប់ (ទំនុកដំកើង ៣២:៨)។**

ដើម្បីអោយលោកអ្នកស្គាល់ផ្លូវដែលត្រូវឈានជើងដើរប្រចាំថ្ងៃ លោកអ្នកចាំបាច់ត្រូវដើរយ៉ាងស្និទ្ធិស្នាលជាមួយនឹងព្រះអង្គ។ នៅពេលដែលយើងដើរជាប់នឹងព្រះអង្គ ភ្នែករបស់ទ្រង់នឹងក្លាយមកជាភ្នែករបស់យើង។

ខាងក្រោមនេះ ព្រះអង្គប្រៀបឧបមាមនុស្សដែលដើរដាច់ចេញពីព្រះអង្គ

ដូចជាសត្វដែលគ្មានប្រាជ្ញា។

**កុំឱ្យឯងធ្វើដូចជាសេះ ឬលាកាត់ ដែលគ្មានប្រាជ្ញា ដែលគេត្រូវដាក់បង្ហៀរ ហើយនឹងបង្ហៀរ ដើម្បីទប់វា ក្រែងវាមិនព្រមមកឯឯងនោះឡើយ (ទំនុកដំកើង៣២:៩)។**

សព្វថ្ងៃ គ្រីស្ទបរិស័ទច្រើនណាស់ដើរជាមួយព្រះ ដូចសេះដាច់បង្ហៀរ។ គេអះអាងថា គេកំពុងដើរក្នុងព្រះហឫទ័យបំណងរបស់ព្រះជាម្ចាស់។ ប៉ុន្តែ មុនគេចាកចេញពីផ្ទះសម្បែង គេមិនបានពិចារណាមើលព្រះបន្ទូល ក៏មិនបានអធិស្ឋានស្វែងរកព្រះហឫទ័យព្រះអង្គអោយព្រះអង្គដឹកនាំគេដែរ។ ព្រះជាម្ចាស់ទ្រង់មានសេចក្តីមេត្តាករុណាយ៉ាងពេញបរិបូរ ព្រះអង្គមិនបណ្តោយអោយកូនរបស់ទ្រង់ ដើរដូចសេះដាច់បង្ហៀរទេ។ ប្រៀបឧបមាដូចជាទ្រង់បានឧបត្ថម្ភគាំទ្រដល់រាស្ត្រព្រះអង្គ ក្នុងហេតុការណ៍ដែលកើតឡើងក្នុងគម្ពីរនាងអែសធើរ ព្រះអង្គនៅតែតម្រង់យើងជារៀងរាល់ថ្ងៃ។ ព្រះអង្គប្រៀបឧបមារាស្ត្រទ្រង់ដែលចូលចិត្តដើរក្រៅបំណងព្រះហឫទ័យរបស់ទ្រង់ដូចជាលាចាស់ល្ងីល្ងើ។ ពេលខ្ញុំចាប់គោមកទឹមរទេះ មុននឹងបរចេញទៅខ្ញុំត្រូវសាកគោមើលសិន។ ខ្ញុំយកខ្សែគោទាំងពីរបួងជាប់នឹងដៃ រួចហើយខ្ញុំយកដៃខ្ញុំច្របាច់គល់កន្ទុយគោ។ បើច្របាច់ហើយ វានៅតែមិនស្ទុះទៀត ខ្ញុំបួងខ្សែទាញថយក្រោយ ហើយយកជន្លួញចាក់ត្រង់ចន្លោះជើងមុខ និងដងខ្លួនវា។ អ្នកខ្លះសួរថា ហេតុ

ដូចម្តេចបានជាចាំបាច់ត្រូវធ្វើយ៉ាងដូច្នោះ? ខ្ញុំត្រូវអោយគោដឹងថា អ្នកប្រើប្រាស់វាមានដៃក្តៅគួសម។ លោកអ្នកបងប្អូនអើយ ប្រៀបឧបមាដូចជាគោដែលយើងទឹមវាចាំបាច់ត្រូវស្គាល់ចិត្តម្ចាស់។ យើងជាកូនរបស់ព្រះជាម្ចាស់ចាំបាច់ត្រូវចម្អែតចិត្ត ចម្អែតព្រលឹង និងចម្អែតអារម្មណ៍របស់យើងដោយសារព្រះបន្ទូលរបស់ព្រះជាម្ចាស់។ តើលោកអ្នកបានចម្អែតព្រលឹងរបស់លោកអ្នកដោយព្រះបន្ទូលរបស់ព្រះជាម្ចាស់ និងការអធិស្ឋានប្រកបយ៉ាងជិតស្និទ្ធជាមួយនឹងព្រះអង្គហើយឬនៅ ព្រឹកមិញ ពេលមុនលោកអ្នកចេញពីផ្ទះ? ព្រះអង្គមានបន្ទូលក្នុងខនេះថា "កុំឱ្យឯងធ្វើដូចជាសេះ ឬលាកាត់ ដែលគ្មានប្រាជ្ញាដែលគេត្រូវដាក់បង្ហាំ ហើយនឹងបង្ហៀរ ដើម្បីទប់វា ក្រែងវាមិនព្រមមកឯឯងនោះឡើយ"។ ព្រះអម្ចាស់ចង់មានបន្ទូលថា កុំអោយយើងប្រព្រឹត្តកិរិយាដូចជាសេះដាច់បង្ហៀរអោយសោះ។

គម្ពីរទំនុកដំកើងជំពូក៣២ បញ្ចប់ដោយសេចក្តីកត់ចំណាំដែលមានសារៈប្រយោជន៍យ៉ាងខ្លាំងចំពោះយើង។

**១០ ឯមនុស្សអាក្រក់គេនឹងមានទុក្ខព្រួយជាច្រើន តែអ្នកណាដែល**
**ទុកចិត្តនឹងព្រះយេហូវ៉ា នោះនឹងមានសេចក្តីសប្បុរសនៅព័ទ្ធជុំ**
**វិញខ្លួន ១១ ឱមនុស្សសុចរិតរាល់គ្នាអើយ ចូរមានចិត្តសប្បាយ**
**ហើយរីករាយឡើងក្នុងព្រះយេហូវ៉ាចុះ អស់អ្នកដែលមានចិត្ត**

**ទៀងត្រង់អើយ ចូរនាំគ្នាស្រែកឡើងដោយអំណរចុះ (ទំនុកដំកើង ៣២:១០-១១)។**

ក្នុងវិនាទីនេះ ខ្ញុំមិនដឹងថា លោកអ្នកបងប្អូនជានរណាទេ ខ្ញុំក៏មិនដឹងថា លោកអ្នកបងប្អូនកំពុងធ្វើដំណើរទៅណាមកណាដែល។ ខ្ញុំដឹងតែម្យ៉ាងថា បើលោកអ្នកទទួលជឿដល់ព្រះអម្ចាស់យេស៊ូវគ្រីស្ទជាអង្គសង្គ្រោះរបស់លោកអ្នកហើយ លោកអ្នកមានលទ្ធភាព អាចផ្លង់ចិត្តរបស់លោកអ្នកឆ្ពោះទៅព្រះជាម្ចាស់ដោយមានសេចក្ដីរីករាយ និងអំណរនៅក្នុងជីវិតរបស់លោកអ្នក។

# ជំពូក ៣៣

*ឆាចចនា បទសរសើរពីបបូរមាត់ ជនដែលមានសេរីភាពក្នុងព្រះគ្រីស្ទ*

នៅក្នុងជំពូកនេះ យើងឃើញមានបទសរសើរតម្កើងដល់ព្រះជាម្ចាស់ ដែលច្រៀងឡើងដោយបបូរមាត់របស់ជនដែលទទួលបានសេរីភាព ព្រះយេស៊ូវប្រទានដល់គេ។ ជននោះ គឺជាជនដែលព្រះជាម្ចាស់ប្រោសលោះពីអំពើបាបរបស់ខ្លួន។ ជនដែលបានទទួលសេចក្ដីសង្គ្រោះតាមរយៈព្រះអម្ចាស់យេស៊ូវ ហើយគេថ្វាយបង្គំដល់ព្រះជាម្ចាស់ដោយទទួលស្គាល់ថាទ្រង់ជាអ្នកមានគុណលើគេ ព្រោះព្រះអង្គបានបង្កើតរូបគេមក។ មិនតែប៉ុណ្ណោះ គេទទួលស្គាល់ដល់ព្រះជាម្ចាស់ថាព្រះអង្គទ្រង់ជាអង្គដែលផ្គត់ផ្គង់ដល់សេចក្ដីត្រូវការរបស់គេរៀងរាល់ថ្ងៃ។ ព្រះអង្គគ្រប់គ្រងជីវិតរបស់គេនៅក្នុងខណៈដែលគេរស់នៅលើផែនដី។ ព្រះអម្ចាស់យេស៊ូវប្រោសយើងអោយរួចពីអំពើបាបរួចហើយរក្សាយើងអោយនៅតែមានភាពស្មោះត្រង់ ជាមួយព្រះអង្គរហូតដល់អវសាន្តនៃជីវិតរបស់យើង។ ដូច្នេះហើយ បានជាអ្នកដែលព្រះជាម្ចាស់ទ្រង់បានប្រោសលោះថ្វាយពាក្យសរសើរដល់ព្រះជាម្ចាស់ ថាភាពធំឧត្តម និងព្រះគុណរបស់ទ្រង់មានតម្លៃមិនអាចយកអ្វីមកកាត់ថ្លៃបាន។ នៅក្នុងគម្ពីរទំនុកដំកើង យើងឃើញមានឧបករណ៍ភ្លេង ដែលត្រូវយកមកសរសើរតម្កើងព្រះអង្គ។ ឧបករណ៍ភ្លេងមានជាអាទិ៍ ស៊ុង

ហើយនិងពិណខ្សែដប់។ គម្ពីរទំនុកដំកើងជំពូក៣៣ ត្រូវចាត់ទុកថាជាគម្ពីរទំនុកដំកើងកំព្រាអ្នកនិពន្ធ ពីព្រោះយើងមិនដឹងថា អ្នកណាមួយជាអ្នកកត់ត្រាទុកគម្ពីរនេះមក។ ប៉ុន្តែ បើតាមសំនួនវោហារនិងខ្លឹមសារដែលសរសេរនៅក្នុងជំពូកនេះ ទំនងដូចជាព្រះបាទដាវីឌ។ ប៉ុន្តែ យើងមិនដឹងច្បាស់ថា ព្រះបាទដាវីឌពិតជាសរសេរជំពូក៣៣ អោយប្រាកដឡើយ។

> **ឱពួកអ្នកសុចរិតអើយ ចូរមានចិត្តរីករាយក្នុងព្រះយេហូវ៉ាចុះ ដ្បិតសេចក្តីសរសើរ នោះសំណំដល់មនុស្សទៀងត្រង់ (ទំនុកដំកើង ៣៣:១)។**

យើងជារាស្ត្ររបស់ព្រះអង្គ ត្រូវមានការអរសប្បាយនៅចំពោះវត្តមានរបស់ព្រះជាម្ចាស់។ គម្ពីរទំនុកដំកើងជំពូក៣៣ ជាបទសរសើរយ៉ាងរីករាយ។

> **ចូរអរព្រះគុណដល់ព្រះយេហូវ៉ា ដោយចាប់ស៊ុង ហើយច្រៀងសរសើរថ្វាយទ្រង់ ដោយដេញពិណខ្សែ១០ (ទំនុកដំកើង៣៣:២)**

ឧបករណ៍តន្ត្រីដែលយកមកលេង ដើម្បីតម្កើងដល់ព្រះជាម្ចាស់នៅក្នុងខនេះគឺស៊ុង ហើយនិងពិណខ្សែដប់។ គេត្រូវច្រៀងសរសើរថ្វាយដល់ព្រះជាម្ចាស់ ដោយ

មានស៊ុងនិងពិណដេញកំដរផង។

**ចូរច្រៀងទំនុកថ្មីថ្វាយទ្រង់ ហើយលេងភ្លេងឱ្យឮរងំដោយប៉ិនប្រសប់ (ទំនុកដំកើង៣៣:៣)។**

យើងត្រូវច្រៀងទំនុកថ្មីថ្វាយទ្រង់ ព្រមទាំងលេងភ្លេងអោយឮរងំដោយប៉ិនប្រសប់។ តើទំនុកថ្មីមានទ្រង់ទ្រាយបែបណា? នៅក្នុងព្រះគម្ពីរទំនុដំកើងមានសម្តែងពីបទទំនាយនៃចម្រៀងដែលត្រូវច្រៀងនៅថ្ងៃអនាគត។ នៅគ្រាខាងមុខ រាស្រ្តរបស់ព្រះជាម្ចាស់នឹងច្រៀងចំរៀងទំនុកថ្មី។ អ្នកដែលច្រៀងចំរៀងទំនុកថ្មីជាមនុស្សថ្មីដែរ។ នៅពេលដែលយើងជាកូនព្រះអង្គ ទៅរស់នៅជាមួយនឹងព្រះអម្ចាស់យេស៊ូវគ្រីស្ទ យើងនឹងទទួលរូបកាយថ្មី។ នៅពេលនោះ បើបងប្អូនណាដែលមិនសូវចេះច្រៀងកាលនៅក្នុងរូបកាយចាស់នៅឡើយ ពិតជាចេះច្រៀងយ៉ាងពិរោះដូចគេដូចឯងដែរ។ គម្ពីរវិវរណៈ៥:៩សម្តែងថា "ពួកទាំងនោះក៏ច្រៀងទំនុក១ថ្មីថា ទ្រង់គួរនឹងយកក្រាំងនេះ ហើយនឹងបកត្រាផង ដ្បិតទ្រង់បានត្រូវគេធ្វើគុត ហើយទ្រង់បានលោះយើងរាល់គ្នាដោយព្រះលោហិតទ្រង់ ចេញពីគ្រប់ទាំងពូជមនុស្ស គ្រប់ភាសា គ្រប់នគរ ហើយពីគ្រប់ទាំងសាសន៍ ថ្វាយដល់ព្រះ"។ អ្នកកត់ត្រាទុកគម្ពីរទំនុកដំកើងជំពូក៣៣ ដាស់តឿនអោយយើងច្រៀងបទចម្រៀងថ្វាយព្រះជាម្ចាស់ ពីព្រោះទ្រង់ជាអង្គនិម្មាបនិក។ ទ្រង់បង្កើតយើងមក។ សព្វថ្ងៃ យើងត្រូវច្រៀងថ្វាយដល់ព្រះជាម្ចាស់ ទោះបីជាចម្រៀង

ចាស់ ឬចម្រៀងនិពន្ធថ្មីក៏ដោយ។ ចម្រៀងទាំងអម្បាលមាណ ដែលយើងច្រៀងនៅលើផែនដីនេះ ទោះចាស់ ទោះនិពន្ធពីយូរយារមកហើយ ឬបទនិពន្ធថ្មី រាប់ថាជាចម្រៀងរបស់រូបកាយចាស់ផ្លាស់មកកើតជាថ្មី។ រីឯបទចម្រៀងទំនុកថ្មី យើងត្រូវច្រៀងនៅស្ថានសួគ៌ ពីព្រោះព្រះអម្ចាស់យេស៊ូវបានប្រោសយើងអោយមានរូបកាយថ្មី សម្លេងថ្មី អ្វីៗទាំងអស់ក៏ថ្មី ពេលយើងទៅនៅជាមួយនឹងព្រះអង្គ។ គម្ពីរវិវរណៈ១៤:៣សម្តែងថា "គេច្រៀងបទ១ថ្មី នៅមុខបល្ល័ង្ក ហើយមុខតួមានជីវិតទាំង៤ នឹងពួកចាស់ទុំដែរ គ្មានអ្នកណាអាចនឹងរៀនបទនោះបានទេ មានតែមនុស្ស១សែន៤មុឺន៤ពាន់នាក់ ដែលទ្រង់លោះពីផែនដីចេញប៉ុណ្ណោះ"។ បទចម្រៀងទំនុកថ្មី ត្រូវច្រៀងនៅគ្រាអនាគត។

នៅក្នុងខនេះ យើងឃើញមានកំណត់មួយដែលនិយាយថា "ហើយលេងភ្លេងឱ្យពួរងំដោយប៉ិនប្រសប់"។ លោកអ្នកបងប្អូនអើយ បើលោកអ្នកបងប្អូនចូលច្រៀងនៅមុខមហាជន សូមច្រៀងអោយពេញសម្លេងហើយអោយត្រូវតាមសង្វាក់ និងខ្ទង់ចូលគេចូលឯងផង។ ចម្រៀងដែលច្រៀងនៅក្នុងក្រុមជំនុំ ត្រូវតែជាចម្រៀងដែលលើកទឹកចិត្តគ្រប់ពេលគ្រប់វេលា។ មិនយ៉ាងដូច្នេះទេ សព្វថ្ងៃនេះ ខ្ញុំសង្កេតឃើញអ្នកឡើងច្រៀងក្នុងព្រះវិហារខ្លះគ្មានអំណោយទាននោះ តែឡើងច្រៀងនឹងគេដែរ។ លុះច្រៀងរអាក់រអួលដូចសម្លេងមានគកឈ្លក់កណ្តៀបស្រូវប្រាំង តាំងឆ្លើយដោះសារខ្លួនថា ចម្រៀងខ្ញុំមិនសូវពិរោះទេ តែចំពោះព្រះជាម្ចាស់វិញ ទ្រង់រាប់ថាពិរោះណាស់។ បើមនុស្សលោកមានបាបស្តាប់មិនពិរោះទៅហើយ តើព្រះជាម្ចាស់ស្តាប់ពិរោះម្តេចទៅនឹងកើត? កុំដោះសារ ត្រូវទទួលស្គាល់ថា យើងគ្មានអំណោយទានខាងចម្រៀងទេ។

បើមិនមានអំណោយទានខាងចម្រៀងទេ សូមកុំឡើងទៅហាលមុខនៅមុខក្រុមជំនុំអោយសោះ។ ចម្រៀងដែលលោកអ្នកច្រៀងច្បាស់ជាមិនលើកទឹកចិត្តដល់អ្នកស្តាប់ទេ។ ផ្ទុយទៅវិញ ចម្រៀងរអាក់រអួលធ្វើអោយទឹកចិត្តរបស់អ្នក ស្តាប់រឹតតែលិចលង់ផុងកាយថែមទៀត។ ចម្រៀងដែលយើងច្រៀងថ្វាយដល់ព្រះជាម្ចាស់ ត្រូវច្រៀងប្រកបដោយអំណោយទាននៃព្រះវិញ្ញាណ ដែលប្រទានមកដល់យើង។ ចម្រៀងប្រភេទនោះលើកទឹកចិត្តដល់អ្នកស្តាប់ ព្រមទាំងធ្វើអោយអ្នកស្តាប់មានទឹកចិត្តចង់សរសើរតម្កើងដល់ព្រះជាម្ចាស់។ បើលោកអ្នកគ្មានអំណោយទានខាងច្រៀងទេ សូមកុំខំប្រឹងអោយសោះ ក្រែងលោនាំអោយអ្នកស្តាប់មានចិត្តដូចគ្រាកទៅវិញ។ ម្យ៉ាងវិញទៀត បើសម្លេងរបស់លោកអ្នកអាចលើកបានត្រឹមខ្ទង់ទាប លោកអ្នកកុំបង្ខំច្រៀងចម្រៀងខ្ទង់អោយសោះ។ បើធ្វើយ៉ាងដូច្នោះមែន អ្នកស្តាប់ច្បាស់ជាមិនទទួលការលើកទឹកចិត្តទេ គឺលង់ក្នុងទឹកចិត្តខ្មាសគេជំនួសលោកអ្នកទៅវិញ។

**ដ្បិតព្រះបន្ទូលនៃព្រះយេហូវ៉ាត្រឹមត្រូវ ហើយបណ្តាកិច្ចការនៃទ្រង់បានធ្វើដោយស្មោះត្រង់ដែរ (ទំនុកដំកើង៣៣:៤)។**

ព្រះបន្ទូលហើយនិងកិច្ចការរបស់ព្រះអង្គ សម្តែងអោយយើងដឹងថា ព្រះអង្គបានបង្កើតអ្វីៗទាំងអស់សម្រាប់មនុស្សលោក។

**ផ្ទៃមេឃបានកើតមក ដោយសារព្រះបន្ទូលព្រះយេហូវ៉ា ហើយពួកបរិវារនៅលើនោះ បានកើតដោយសារខ្យល់ ពីព្រះឱស្ឋទ្រង់ (ទំនុកដំកើង៣៣:៦)។**

ព្រះបន្ទូលរបស់ព្រះជាម្ចាស់មានចេស្តា។ ពេលខ្លះ ក្នុងពេលថ្វាយបង្គំព្រះអង្គខ្ញុំឃើញមានមនុស្សឡើងច្រៀង ហើយពេលគេច្រៀងគេដាច់សម្លេង។ ការច្រៀងរអាក់រអួល មិនបានផ្តល់នូវការលើកទឹកចិត្តដល់អ្នកស្តាប់ បែរជានាំអោយមានការរំខានចិត្តទៅវិញ។ ព្រះជាម្ចាស់បង្កើតអ្វីៗសព្វសារពើដោយសារព្រះបន្ទូល មិនមែនសម្រាប់បំផ្លាញទេ។ ព្រះអង្គបានធ្វើអោយលោកសន្និវាសយើងមានចេញជារូបរាងដូចយើងឃើញសព្វថ្ងៃ ដើម្បីស្អាងចិត្តមនុស្សឡើង។ គម្ពីរលោកុប្បត្តិ១:៣សម្តែងថា "នោះព្រះទ្រង់មានបន្ទូលថា ចូរឱ្យមានពន្លឺឡើង ដូច្នេះពន្លឺក៏មានឡើង"។ បច្ចុប្បន្នយើងឃើញមានពន្លឺច្រើនបែបច្រើនយ៉ាង ដូចជាពន្លឺថ្ងៃ ពន្លឺខែ ពន្លឺផ្កាយ និងពន្លឺអគ្គិសនី។ល។... ពន្លឺទាំងនោះកើតមានមកទល់សព្វថ្ងៃនេះ បន្ទាប់ពីព្រះជាម្ចាស់មានបន្ទូលថា "ចូរឱ្យមានពន្លឺឡើង"។ ព្រះជាម្ចាស់មានបន្ទូលរួចហើយ មាបនកម្មនានាកើតចេញជារូបរាងដូចយើងឃើញមានសព្វថ្ងៃ។ បន្លែបង្កា សត្វគ្រប់ប្រភេទ និងមនុស្សជាមាបនកម្មដែលព្រះបង្កើតដោយសារព្រះបន្ទូលរបស់ទ្រង់។ ព្រះបន្ទូលរបស់ទ្រង់មានចេស្តាយ៉ាងខ្លាំងមហិមា។ ព្រះអម្ចាស់យេស៊ូវគ្រីស្ទបានរួមចំណែកជាមួយព្រះវរបិតា និងព្រះវិញ្ញាណបរិសុទ្ធបង្កើតមាបនវត្ថុសព្វបែបសព្វយ៉ាង ដូចយើងជួបប្រទះនៅក្នុងជីវិត

រស់នៅប្រចាំថ្ងៃរបស់យើង។ ខ្ញុំមិនដឹងថាព្រះអង្គបង្កើតមាបនវត្ថុទាំងនោះដោយវិធីណាទេ តែខ្ញុំជឿយ៉ាងច្បាស់ឥតសង្ស័យថា តាមរយៈព្រះបន្ទូលរបស់ទ្រង់ ទ្រង់បានបង្កើតរបស់ទាំងនោះមក។

**ព្រះយេហូវ៉ាទ្រង់ធ្វើឱ្យសេចក្តីប្រឹក្សានៃអស់ទាំងនគរបានថ្លស់ការ ទ្រង់ធ្វើឱ្យគំនិតនៃជនទាំងឡាយបានទៅជាឥតការ (ទំនុកដំកើង ៣៣:១០)។**

សព្វថ្ងៃ នៅអគារអង្គការសហប្រជាជាតិ គេបានជ្រើសរើសយកខគម្ពីរមួយមកសរសេរជាបដារ។ ឯខគម្ពីរនោះ គឺគម្ពីរអេសាយ២:៤។ គេកាត់ខ្លះយកមកសរសេរថា "...គេនឹងយកដាវរបស់ខ្លួនដំធ្វើជាផាលនង្គ័ល ហើយលំពែងគេធ្វើជាដង្កាវិញ នគរ១នឹងមិនលើកដាវទាស់នឹងនគរ១ទៀតឡើយ ក៏មិនហាត់រៀនធ្វើសឹកសង្គ្រាមទៀតដែរ"។ ខ្ញុំយល់ថា អ្នកជ្រើសរើសយកខគម្ពីរខាងលើមកសរសេរនៅក្នុងអគារអង្គការសហប្រជាជាតិ មិនសមហេតុសមផលទេ។ អង្គការសហប្រជាជាតិមិនបានដំកាំភ្លើងធ្វើផាលទេ។ ផ្ទុយទៅវិញ គេដំផាលធ្វើកាំភ្លើង។ ខ្ញុំយល់ថា គេគួរយកខគម្ពីរទំនុកដំកើង៣៣:១០ សរសេរនៅលើអគារអង្គការសហប្រជាជាតិ ដ្បិតខនេះសម្តែងថា "ព្រះយេហូវ៉ាទ្រង់ធ្វើឱ្យសេចក្តីប្រឹក្សានៃអស់ទាំងនគរ បានថ្លស់ការ ទ្រង់ធ្វើឱ្យគំនិតនៃជនទាំងឡាយបានទៅជាឥតការ"។ ពេលមុនអង្គការសហប្រជាជាតិសព្វថ្ងៃកើតជា

រូបរាង គេបានបង្កើតសន្និកបាតប្រជាជាតិ។ បន្ទាប់មកទៀត គេបានបង្កើតអង្គការមួយទៀតហៅថាសន្និសីទសន្តិភាពក្រុងឡាអេ។ ក្រោយមកទៀតទើបគេបង្កើតអង្គការសហប្រជាជាតិដូចជាយើងឃើញមានសព្វថ្ងៃនេះ។ អង្គការទាំងពីរដែលកើតខាងដើមត្រូវសាបសូន្យទៅ។ បើតាមពន្លឺនៃព្រះបន្ទូលរបស់ព្រះអង្គ ដែលសម្តែងអោយឃើញនៅក្នុងខនេះខ្ញុំយល់ថា អង្គការសហប្រជាជាតិសព្វថ្ងៃ ក៏ត្រូវសាបសូន្យក្នុងថ្ងៃណាមួយជាមិនខាន។ ឯមូលហេតុដែលអង្គការសហប្រជាជាតិត្រូវសាបសូន្យ ពីព្រោះមនុស្សដែលអង្គុយនៅអង្គការសហប្រជាជាតិបានបោះបង់ចោលព្រះជាម្ចាស់។

**មានពរហើយ នគរណាដែលយកព្រះយេហូវ៉ាទុកជាព្រះរបស់ខ្លួន គឺជាសាសន៍ដែលទ្រង់បានរើស ទុកជាមរដករបស់ទ្រង់ (ទំនុកដំកើង៣៣:១២)។**

យើងចង់ឃើញខគម្ពីរនេះសរសេរនៅទីណាមួយ ក្នុងនគររបស់យើង ដើម្បីអោយតំណាងរាស្ត្រ និងរាជការបានមើលហើយមើលទៀត ក្រែងលោភ្លេច។

**ព្រះយេហូវ៉ាទ្រង់ទតមកពីលើស្ថានសួគ៌ ទ្រង់ឃើញមនុស្សលោកទាំងអស់ (ទំនុកដំកើង៣៣:១៣)។**

បើតាមបទគម្ពីរខាងលើនេះ ព្រះជាម្ចាស់កំពុងតែទតមើលអង្គការសហប្រជាជាតិ។ ព្រះអង្គទតមើលប្រធានាធិបតីសហរដ្ឋអាមេរិក និងអ្នកប្រមុខនៃប្រទេសមហាអំណាចនានា។ ព្រះអង្គទតមើលឃើញរដ្ឋសភាកំពុងធ្វើការ។ ព្រះអង្គទតមើលប្រធានាធិបតី និងនាយករដ្ឋមន្ត្រីគ្រប់ប្រទេស។ ព្រះអង្គទតឃើញលោកអ្នក ព្រះអង្គទតឃើញរូបខ្ញុំ។ គ្មាននរណាម្នាក់នៅលើលោកនេះ អាចគេចពីខ្សែព្រះនេត្ររបស់ទ្រង់បានសូម្បីមួយវិនាទីនៃជីវិតរបស់គេ ក៏មិនអាចបានដែរ។

**គ្មានស្តេចណាបានសង្គ្រោះ ដោយមានពលទាហានច្រើនឡើយ**
**មនុស្សខ្លាំងពូកែក៏មិនបានរួច ដោយមានកំឡាំងយ៉ាងខ្លាំងនោះ**
**ដែរ (ទំនុកដំកើង៣៣:១៦)។**

ស្តេចណាប៉ូឡេអុងជាស្តេចល្មោភសង្គ្រាម។ ស្តេចនេះបានអះអាងថា ព្រះជាម្ចាស់កាន់ជើងលោក។ ប៉ុន្តែ ការសន្និដ្ឋានរបស់ស្តេចអង្គនេះខុសស្រឡះ ពីព្រោះនៅសមរភូមិវ៉ាធែរលូ ព្រះបាទណាប៉ូឡេអុងបានចាញ់សង្គ្រាមយ៉ាងដំណំ។ ព្រះជាម្ចាស់មិនកាន់ជើងស្តេចណាដែលល្មោភសង្គ្រាមទេ។ មិនតែប៉ុណ្ណោះ ប្រទេសដែលមានអាវុធនិងគ្រាប់បែកបរម៉ាណូខ្លាំងជាងគេ ក៏មិនធានាថាព្រះជាម្ចាស់គង់នៅជាមួយគេដែរ។

**មើល ព្រះនេត្រនៃព្រះយេហូវ៉ាទតមកលើអស់អ្នកដែលកោត**

**ខ្លាចដល់ទ្រង់ គឺមកលើពួកអ្នកដែលសង្ឃឹមដល់សេចក្តីសប្បុរស ទ្រង់ (ទំនុកដំកើង៣៣:១៨)។**

តើលោកអ្នកបានទទួលការកំសាន្តចិត្តខ្លះដែរឬទេថា ព្រះនេត្រនៃព្រះយេហូវ៉ា កំពុងទតមកលើអស់អ្នកដែលកោតខ្លាចដល់ទ្រង់ គឺមកលើពួកអ្នកដែលសង្ឃឹមដល់សេចក្តីសប្បុរសរបស់ទ្រង់។ ចូរមានចិត្តសង្ឃឹមឡើង!

**ដ្បិតចិត្តយើងខ្ញុំនឹងរីករាយឡើងក្នុងទ្រង់ ពីព្រោះយើងខ្ញុំបានទុកចិត្តដល់ព្រះនាមបរិសុទ្ធរបស់ទ្រង់ហើយ (ទំនុកដំកើង៣៣:២១)។**

ជនណាដែលទុកចិត្តដល់ព្រះជាម្ចាស់ ចិត្តរបស់អ្នកនោះមានសេចក្តីសុខសាន្ត។ សេចក្តីអំណរ សេចក្តីរីករាយ និងសេចក្តីជ្រះថ្លានៅក្នុងចិត្តកើតមាននៅក្នុងចិត្តអ្នកនោះ។ ធ្វើដូចម្តេចដើម្បីអោយយើងមានសេចក្តីសុខទាំងនោះកើតឡើងដល់យើង? សូមលោកអ្នកចម្អែតព្រលឹង ចម្អែតចិត្ត ចម្អែតមនោសញ្ចេតនារបស់លោកអ្នក ដោយសារព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដែលសម្តែងនៅក្នុងគម្ពីរទំនុកដំកើងចុះ។ យ៉ាងដូច្នោះ លោកអ្នកមិនចាំបាច់រត់ដូចឆ្កែដំបៅក ចូលរៀននៅត្រង់នេះបន្តិច ចូលរៀននៅត្រង់នោះបន្តិច ចូលសិក្ខាសាលានេះ ទៅចូលសិក្ខាសាលានោះ នាំហត់នឿយអស់លុយអស់កាក់ឥតប្រយោជន៍ទេ។ លោកគ្រូគង្វាលម្នាក់មានប្រសាសន៍ថា បញ្ញាផ្លូវ

ចិត្ត និងបញ្ហាដែលមាននៅក្នុងក្រុមជំនុំអាចដោះស្រាយបានរហូតដល់ ៩៩.៤% បើពួកអ្នកជឿទុកចិត្តលើព្រះបន្ទូលរបស់ព្រះជាម្ចាស់។ ការទុកចិត្តលើព្រះ បន្ទូលមានន័យថា ផ្ទេរជំនឿអោយមកជាការប្រព្រឹត្តសុចរិតក្នុងការរស់នៅប្រចាំថ្ងៃ។ ដូច្នេះ ការចេះព្រះបន្ទូលស្ទួត្រចងចាំរត់មាត់មិនធានាថា លោកអ្នកបងប្អូនពិតជាអនុវត្តតាមព្រះបន្ទូលរបស់ព្រះអង្គទេ។

យើងស្លេះការសិក្សាគម្ពីរទំនុកដំកើងត្រឹមណេះសិនចុះ។ ទំរាំយើងជួបគ្នាលើកក្រោយ សូមព្រះជាម្ចាស់ប្រទានពរដ៏ធំឧត្តម ដល់លោកអ្នកបងប្អូនគ្រប់ៗគ្នា។ "ដើរជាមួយនឹងព្រះ ពិតជាប្រទះនឹងព្រះយេស៊ូវជាមិនខាន!"